雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.140

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY
PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7539 ថ្ងៃសុក្រ ទី 19 ខែ មករា ឆ្នាំ 2018

## កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គធ្វើឱ្យមុខវិជ្ជាភាសាប្រទេសអាស៊ីអាគ្នេយ៍កាន់តែមានប្រជាប្រិយភាពនៅប្រទេសចិន



ថ្នាក់សិក្សាភាសាខ្មែរនៅសាកលវិទ្យាល័យយូនណាន (រូបថត ដោយ Liu Rong )

និស្សិតឈ្មោះ ចាំង វៃគួ មកពីស្រុកស្វយ័តជនជាតិហានីនិងជនជាតិ យីហុងហឺខេត្តយូនណាន ។ មុននឹងទៅរៀនភាសាភូមានៅសាកលវិទ្យាល័យ គាត់មានការយល់ដឹងតិចតួចអំពីប្រទេសមីយ៉ាន់ម៉ា ។ គាត់បានបញ្ជាក់ថា ពេលដំបូងខ្ញុំគ្មានគំនិតអ្វីចំពោះការរៀនភាសាភូមាទេ ។ តែបន្ទាប់ពីរៀនបានមួយឆ្នាំនៅពេលចាប់ផ្តើមរៀបចំឯកសារស្នើសុំដើម្បីទៅបន្តការសិក្សានៅឯបរទេសខ្ញុំគិតថា ខ្ញុំពិតជាមានសំណាងណាស់ដែលអាចមានឱកាសរៀនភាសាភូមា ។

ក្នុងអំឡុងពេលពីខែធ្នូ ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២ ចាំង វៃគួ បានទៅបន្តការសិក្សានៅសាកលវិទ្យាល័យភាសាបរទេសរ៉ុង ហ្គូន នៃប្រទេសមីយ៉ាន់ម៉ា ។ គាត់បានប្រាប់អ្នកកាសែតថា នៅពេលរៀននៅប្រទេសមីយ៉ាន់ម៉ាខ្ញុំបានទទួលផលប្រយោជន៍ដ៏ច្រើន ។ ខ្ញុំមិនគ្រាន់តែបានមានការយល់ដឹងច្រើនអំពីប្រទេសមីយ៉ាន់ម៉ាប៉ុណ្ណោះទេថែមទាំងបានស្គាល់មិត្តបរទេសច្រើនទៀតផង ។ ជាពិសេសការសិក្សានៅឯបរទេសបានជួយបង្កើនចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំ។

អ្វីដែលធ្វើឱ្យ ចាំង វៃគួ គិតមិនដល់នោះគឺនៅឆ្នាំ២០១៣ ពេលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យគាត់ជម្រើសច្រើនក្នុងការរកការងារធ្វើ។ ក្រោយពីគិតគូរពិចារណាដោយល្អិតល្អន់គាត់បានសម្រេចចិត្តទៅធ្វើការនៅសាកលវិទ្យាល័យភាសាបរទេសក្វាងតុង ។ សព្វថ្ងៃគាត់ជាគ្រូបង្រៀនភាសាភូមានៅសាលានោះ ។

តាមពិត នៅពេលបញ្ចប់ការសិក្សា ចាំង វៃគួ និងមិត្តរួមថ្នាក់ ២៨ នាក់សុទ្ធតែរកបានការងារធ្វើដែលមានពាក់ព័ន្ធនឹងភាសាភូមា ។ គាត់បានបញ្ជាក់ទៀតថា ការស្ថាបនា "ខ្សែក្រវាត់មួយ និងផ្លូវមួយ" និងកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គបានធ្វើឱ្យធនធានមនុស្សដែល ចេះ និយាយភាសាប្រទេសអាស៊ីអាគ្នេយ៍កាន់តែមានប្រជាប្រិយភាពនៅក្នុងប្រទេស ចិន ។

នៅខែមីនា ឆ្នាំ២០១៦យន្តការស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គបានត្រូវបង្កើតឡើងជាផ្លូវការ ។ យន្តការដ៏មានសារសំខាន់នេះបានបង្កើនទំនុកចិត្តផ្នែកនយោបាយរវាងប្រទេសទន្លេឡានឆាង-មេគង្គទាំង៦ហើយបានធ្វើឱ្យប្រទេសទាំងនោះមានកិច្ចសហប្រតិបត្តិការកាន់តែស្អិតល្មួតលើវិស័យសេដ្ឋកិច្ចនិងពាណិជ្ជកម្មមានទំនាក់ទំនងកាន់តែជិតស្និទ្ធព្រមទាំងបានបង្កើតជានិន្នាការអភិវឌ្ឍន៍នៃការធ្វើកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនិងបានទទួលនូវលទ្ធផលជាផ្លែផ្កាកាន់តែច្រើនថែមទៀត ។

លោកស្រីសាស្ត្រាចារ្យ ចាវ ជូឡាន ដែលជាអ្នកជំនាញការវិទ្យាស្ថានសិក្សាស្រាវជ្រាវតំបន់អាស៊ីអាគ្នេយ៍នៃបណ្ឌិត្យសភាសង្គមសាស្ត្រខេត្តយូនណានមានប្រសាសន៍ថាចំណុចគន្លឹះសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គគឺការជឿទុកចិត្តលើគ្នានិងការយោគយល់គ្នាទៅវិញទៅមក ។ ធនធានមនុស្សដែលចេះនិយាយភាសាប្រទេសអាស៊ីអាគ្នេយ៍មានការយល់ដឹងច្រើនអំពីប្រព័ន្ធគំនិតរបស់ប្រជាជននៃប្រទេសទាំងនោះហើយអាចយោគយល់និងពិគ្រោះពិភាក្សាជាមួយពួកគេដោយមានប្រសិទ្ធភាពខ្ពស់ជៀសវាងកុំឱ្យកើតមានការច្រឡំគ្នានិងអាចជំរុញការអភិវឌ្ឍដោយរួមគ្នា។ ដូច្នេះការបណ្តុះបណ្តាលធនធានមនុស្សដែលចេះនិយាយភាសាប្រទេសអាស៊ីអាគ្នេយ៍គឺជាមធ្យោបាយដ៏សំខាន់ដែលមិនអាចជំនួសបានសម្រាប់ជំរុញនិងពង្រឹងកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គដោយមានប្រសិទ្ធភាពខ្ពស់ ។

ខេត្តយូនណានស្ថិតនៅជាប់នឹងប្រទេសមីយ៉ាន់ម៉ា ឡាវនិងវៀតណាម។ នៅឆ្នាំ២០១៣ សាលាខេត្តយូនណានបានបង្កើតគណៈកម្មាធិការណែនាំ ការអប់រំភាសាបរទេសដែលប្រើប្រាស់មិនទូទៅនៃសាលាឧត្តមសិក្សាខេត្តយូនណានដើម្បីជំរុញការអនុវត្តការងារបណ្តុះបណ្តាលអំពីភាសាបរទេសដែលប្រើប្រាស់មិនទូទៅនៅខេត្តយូនណាន ។ គិតមកដល់ចុងឆ្នាំ២០១៤សាលាឧត្តមសិក្សាខេត្តយូនណានបានបង្កើតមូលដ្ឋានបណ្តុះបណ្តាលធនធានមនុស្សអន្តរជាតិចំនួន១១មូលដ្ឋានដែលបានធ្វើឱ្យការបណ្តុះបណ្តាលធនធានមនុស្សដែលចេះនិយាយភាសាប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងទទួលបាននូវសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ហើយបានជ្រើសរើសឱ្យនិស្សិតចំនួន៥,៥ម៉ឺននាក់រៀនភាសាបរទេសដែលប្រើប្រាស់មិនទូទៅនៅសាកលវិទ្យាល័យផ្សេងៗក្នុងខេត្តយូនណាន។ សព្វថ្ងៃសាលាឧត្តមសិក្សាខេត្តយូនណានបានបង្កើតកម្មវិធីសិក្សាភាសាបរទេសដែលប្រើប្រាស់មិនទូទៅជាង១០ភាសា រួមមានភាសាថៃ ភូមា វៀតណាម ឡាវ និងខ្មែរជាដើម ។ ជារៀងរាល់ឆ្នាំ មាននិស្សិតមួយចំនួនធំរៀនភាសាបរទេសដែលប្រើប្រាស់មិនទូទៅនៅសាកលវិទ្យាល័យផ្សេងៗក្នុងខេត្តយូនណាន។ បច្ចុប្បន្នក្រោយពីបញ្ចប់ការសិក្សាពីសាលារៀនពួកគេតែងតែមានការងាយស្រួលក្នុងការរកការងារធ្វើ ៕

**ដោយ : យ៉ាវ ពឹង (ស៊ីនហួចិន)**

## អ្នកដំណើរអាច "ស្កេនមុខ" ចូលស្ថានីយរថភ្លើងខាងត្បូងក្រុងគុនមីង



អ្នកដំណើរកំពុងតែឆ្លងកាត់ អ្នកត្រួតពិនិត្យសំបុត្រតាមរយៈបច្ចេកវិជ្ជាទទួលស្គាល់មុខ (រូបថតដោយ Huang Zhechun )

បន្ទាប់ពីស្ថានីយរថភ្លើងខាងត្បូងក្រុងគុនមីងត្រូវដាក់ឱ្យប្រើប្រាស់រៀងមក អ្នកគ្រប់គ្រងស្ថានីយរថភ្លើងនេះ បានខិតខំកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់អ្នកដំណើរ ។ ពេលថ្មីៗនេះម៉ាស៊ីនពិនិត្យអត្តសញ្ញាណអ្នកដំណើរដោយស្វ័យប្រវត្តិចំនួនប្រាំបីគ្រឿងបានត្រូវដាក់ឱ្យប្រើប្រាស់នៅច្រកចូលខាងលិច និងខាងជើងនៃស្ថានីយរថភ្លើងនេះ ។ អ្នកដំណើរអាចយកសំបុត្ររថភ្លើង និងអត្តសញ្ញាណប័ណ្ណទៅទទួលការពិនិត្យដោយស្វ័យប្រវត្តិ ហើយ "ស្កេនមុខ" តាមយរយៈម៉ាស៊ីនដ៏ជឿនលឿននេះ រួចក៏អាចចូលក្នុងស្ថានីយរថភ្លើងដោយមានភាពងាយស្រួល ។ ម៉ាស៊ីនទាំងនេះនឹងអាចជួយលើកកម្ពស់នូវប្រសិទ្ធភាព និងភាពទៀងទាត់នៃការងារសម្គាល់អត្តសញ្ញាណរបស់អ្នកដំណើរ ៕

## មនុស្សយន្តជឿនលឿនបង្ហាញខ្លួននៅព្រលានយន្តហោះអន្តរជាតិឆាងស្លួយក្រុងគុនមីង

ពេលថ្មីៗនេះ មនុស្សយន្តជឿនលឿន២០គ្រឿងបានបង្ហាញខ្លួនជាសាធារណៈនៅព្រលានយន្តហោះអន្តរជាតិ ឆាងស្លួយ ក្រុងគុនមីង ដើម្បីផ្តល់សេវាកម្មអំពីការផ្តល់ព័ត៌មានជើងហោះហើរ ណែនាំអំពីការបំពេញបែបបទផ្សាយព័ត៌មានអំពីការរក្សាសន្តិសុខ ទទួលស្វាគមន៍ភ្ញៀវ និងផ្សព្វផ្សាយទេសចរណ៍ខេត្តយូនណានជាដើម ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា មនុស្សយន្តទាំងនោះគឺសិក្សាស្រាវជ្រាវដោយក្រុមហ៊ុន UBTECH ក្រុងគុនមីង ដោយយោងតាមតម្រូវការជាក់ស្តែងរបស់ព្រលានយន្តហោះអន្តរជាតិ ឆាងស្លួយ ក្រុងគុនមីង ហើយនឹងសាកល្បងដំណើរការរយៈពេលកន្លះឆ្នាំនៅព្រលានយន្តហោះនេះ ។ សព្វថ្ងៃមនុស្សយន្តទាំងនេះបានត្រូវដាក់ឱ្យប្រើប្រាស់នៅកន្លែងចំនួន១១ក្នុងអគារអ្នកដំណើរលេខ៣ នៃព្រលានយន្តហោះ ឆាងស្លួយ រួមមានសាលទទួលភ្ញៀវ កន្លែងរង់ចាំពិនិត្យសន្តិសុខមជ្ឈមណ្ឌលពាណិជ្ជកម្ម ច្រកពិនិត្យសន្តិសុខជើងហោះហើរក្នុងស្រុក និងច្រកពិនិត្យសន្តិសុខជើងហោះហើរអន្តរជាតិជាដើម ៕

**ដោយ ហ៊្វូ សៀវយ៉ុង**

## គម្រោងចំនួនប្រាំមួយរបស់ខេត្តយូនណានទទួលពានរង្វាន់បច្ចេកវិជ្ជាទំនើបចិន

ពេលថ្មីៗនេះ លទ្ធផលអំពីពានរង្វាន់បច្ចេកវិជ្ជាទំនើបចិនឆ្នាំ២០១៧ បានត្រូវប្រកាសជាសាធារណៈនៅរដ្ឋធានីប៉េកាំង ។ គម្រោងចំនួនប្រាំមួយរបស់ខេត្តយូនណានបានទទួលរង្វាន់ថ្នាក់លេខ២ ក្នុងនោះមានគម្រោងមួយដែលខេត្តយូនណានជាអ្នកទទួលខុសត្រូវ ហើយមានគម្រោងប្រាំមួយទៀត ដែលខេត្តយូនណានជាអ្នកចូលរួមសិក្សាស្រាវជ្រាវ ។

គម្រោងដែលខេត្តយូនណានធ្វើជាអ្នកទទួលខុសត្រូវនោះ គឺជាគម្រោងសិក្សាស្រាវជ្រាវអំពីបច្ចេកទេសគន្លឹះសម្រាប់ការពារដំណាំកុំឱ្យសត្វស៊ី ដែលដឹកនាំដោយលោកបណ្ឌិតសភាចារ្យ ជូ យូវយ៉ុង មកពីបណ្ឌិត្យសភាវិស្វកម្មចិន ហើយទទួលបន្ទុកសិក្សាស្រាវជ្រាវដោយសាកលវិទ្យាល័យកសិកម្មយូនណាន។ គម្រោងដែលខេត្តយូនណានចូលរួមសិក្សាស្រាវជ្រាវទាំងប្រាំនោះ គឺបច្ចេកទេសវាយតម្លៃចំពោះធនធានពូជផ្សិត និងសម្រាំងពូជផ្សិតសម្រាប់ហូបបច្ចេកទេសបង្កើត និងប្រើប្រាស់ប្រព័ន្ធតាមដានការបំពុលបរិស្ថានដោយធាតុ N-P នៅស្រែចម្ការក្នុងប្រទេសចិន ការសិក្សាស្រាវជ្រាវ និងប្រើប្រាស់បច្ចេកទេសគន្លឹះអំពីថ្នាំចិនសៃ Pseudo-Ginseng បច្ចេកទេសគន្លឹះអំពីផលិតផលវិនិច្ឆ័យ ព្យាបាល និងបង្ការជំងឺអេដស៍ និងបច្ចេកទេសថែរក្សាពូជស្រូវព្រៃក្នុងប្រទេសចិន ៕ **ដោយ ជី ជឹង**

## មន្ទីរពេទ្យហ្វូវ៉ៃខេត្តយូនណានជួយព្យាបាលជំងឺដោយឥតគិតថ្លៃឱ្យកុមារខ្មែរ



បុគ្គលិកសុខាភិបាលកំពុងត្រួតពិនិត្យស្ថានភាពទូទៅរបស់កុមារ កម្ពុជាមួយរូប ដែលកំពុងតែប្រឈម នឹងជំងឺបេះដូង មុនពេលវះកាត់ (រូបថត ដោយ Chen Xinlong )

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ កុមារខ្មែរប្រាំនាក់បានទទួលការវះកាត់ដោយឥតគិតថ្លៃនៅមន្ទីរពេទ្យ ហ្វូវ៉ៃ ខេត្តយូនណាន ។ ការវះកាត់ទាំងនោះសុទ្ធតែបានទទួលការជោគជ័យ ។ តាមរយៈកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការសុខាភិបាលនិងសម្រាលកូនតាមផែនការរបស់ប្រទេសចិននិងក្រសួងសុខាភិបាលកម្ពុជាក្នុងរយៈពេល៣ឆ្នាំខាងមុខ មន្ទីរពេទ្យ ហ្វូវ៉ៃ ខេត្តយូនណាននឹងជួយព្យាបាលជំងឺដោយឥតគិតថ្លៃឱ្យកុមារខ្មែរ១០០ នាក់ដែលមានជំងឺបេះដូងតាំងពីកើត ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា កាលពីថ្ងៃទី២០ ដល់ទី២៨ ខែធ្នូ ឆ្នាំ២០១៧ មន្ទីរពេទ្យ ហ្វូវ៉ៃ ខេត្តយូនណានបានទទួលការអញ្ជើញពីដៃគូសហប្រតិបត្តិការនៅប្រទេសកម្ពុជា ហើយបានចាត់បញ្ជូនឱ្យក្រុមសុខាភិបាលដែលមានសមាជិក១២នាក់ ទៅធ្វើការនៅប្រទេសកម្ពុជា ដើម្បីពិនិត្យជំងឺឱ្យកុមារខ្មែរដែលមានជំងឺបេះដូងតាំងពីកើតនៅខេត្តបាត់ដំបង និងតំបន់ជុំវិញ ។ គ្រូពេទ្យចិនបានទៅធ្វើការនៅសាលាខ្មែរចំនួន២១ ហើយបានរកឃើញ កុមារខ្មែរ២៦នាក់ ដែលមានជំងឺ បេះដូងតាំងពីកើត ។ ក្រោមការគាំទ្រពីរដ្ឋាភិបាលនៃប្រទេសទាំងពីរមានកុមារខ្មែរ ប្រាំពីរនាក់ បានត្រូវបញ្ជូនទៅមន្ទីរ ពេទ្យ ហ្វូវ៉ៃ ខេត្តយូនណានដើម្បីទទួលការវះកាត់ដោយឥតគិតថ្លៃនៅទីនោះ ។

លោកស្រី ឆឹន សៀវវិន មេក្រុមគិលានុបដ្ឋាយិកាក្នុងមន្ទីរពេទ្យ ហ្វូវ៉ៃ ខេត្តយូនណានបានបញ្ជាក់ថា ក្នុងចំណោមកុមារខ្មែរទាំងប្រាំពីរនាក់ កុមារពីរនាក់មានអាការៈ និងស្ថានភាពជំងឺស្មុគស្មាញ ហើយត្រូវរកឱកាសល្អមួយ ទើបអាចធ្វើការវះកាត់បាន ។

អ្នកទទួលខុសត្រូវនៃមន្ទីរពេទ្យហ្វូវ៉ៃខេត្តយូនណានបានបញ្ជាក់ថាមន្ទីរពេទ្យហ្វូវ៉ៃ មិនត្រឹមតែជួយព្យាបាលជំងឺឱ្យកុមារខ្មែរប៉ុណ្ណោះទេហើយក៏បានយកចិត្តទុកដាក់ចំពោះការរស់នៅរបស់ពួកគេដែរ។ អ្នកថែទាំអ្នក ជំងឺក្នុងមន្ទីរពេទ្យនឹងកំដរ និងថែរក្សាកុមារខ្មែរទាំងប្រាំពីរនាក់រហូតដល់ពេលចេញពី មន្ទីរពេទ្យ ដើម្បីជួយពួកគេ ដោះស្រាយបញ្ហាផ្សេងៗនៅពេលព្យាបាលជំងឺក្នុងប្រទេសចិន ។ ម្យ៉ាងទៀតកុមារខ្មែរដែលមានជំងឺបេះដូងផ្សេងៗទៀតនឹងត្រូវបញ្ជូនមកមន្ទីរពេទ្យយើងនឹងទទួលការវះកាត់ជាបន្តបន្ទាប់៕ **ដោយ ឈូ ផាន**